# តំបន់អទិភាពក្នុងការអភិវឌ្ឍទេសចរណ៍កម្ពុជា

Priority areas for Cambodia tourism development

ហេង សុភី មន្ត្រីស្រាវជ្រាវ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

## I. សេចក្តីផ្តើម

វិស័យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ គឺជាវិស័យអាទិភាពមួយត្រូវបានកំណត់ នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ វិស័យទេសចរណ៍រួមចំណែកកសាងសេដ្ឋកិច្ច សង្គម ផ្តល់ឱកាសការងារប្រាក់ចំណូលលើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រ។ ទេសចរណ៍ត្រូវបានទទួលស្គាល់ថាជា "មាសបៃតង" ជាផ្នែកដ៏សំខាន់នៃសេដ្ឋកិច្ចបៃតង ដែលចំណូលនៃវិស័យនេះ ត្រូវបានចាក់បញ្ចូលភ្លាមៗទៅក្នុងចរន្តសេដ្ឋកិច្ចជាតិ រួមចំណែកជំរុញកំណើនផលិតផលក្នុងស្រុកសរុប (GDP) និងធ្វើឱ្យមានលំនឹងផ្នែកជញ្ជីងពាណិជ្ជកម្ម។ ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវរួមចំណែកយ៉ាងសកម្មដល់កិច្ចអភិវឌ្ឍថែរក្សា ការពារនិងអភិរក្សសម្បត្តិ វប្បធម៌ប្រវត្តិសាស្ត្រ និងធនធានធម្មជាតិ។ ម្យ៉ាងទៀតការរីកលូតលាស់នៃទេសចរណ៍ជួយលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ ការពង្រឹងនិងពង្រីកមិត្តភាព សាមគ្គីភាព កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងអន្តរជាតិ។

ជាការពិតកម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ មានសក្តានុពលយ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ដោយឈរលើប្រភពធនធាន "វប្បធម៌និងធម្មជាតិ" ការឯកភាពជាតិ ស្ថិរភាពនយោបាយ សន្តិសុខ និងសុវត្ថិភាពល្អ។ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការបន្តជំរុញយ៉ាងសកម្មសន្ទុះរីកចម្រើននៃវិស័យទេសចរណ៍សំដៅរួមចំណែកពង្រឹងមូលដ្ឋានសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០ បានដាក់ចេញដើម្បីបង្ហាញថែមទៀត នូវឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តភាព និងយកវិស័យនេះជាវិស័យអាទិភាពមួយក្នុងការរួមចំណែកកសាងសេដ្ឋកិច្ចសង្គម។

## II. ការអភិវឌ្ឍទេសចរណ៍តាមតំបន់អាទិភាព

ការអភិវឌ្ឍផលិតផលទេសចរណ៍ ត្រូវបានកំណត់តាមប្រភេទផលិតផល និងតាមតំបន់ឬច្រករបៀងសំខាន់ៗ ដោយមានការសិក្សាវិភាគច្បាស់លាស់ទៅលើប្រភពធនធានសក្តានុពល ភាពទាក់ទាញផ្នែកពាក់ព័ន្ធនិងផលប៉ះពាល់សេដ្ឋកិច្ចសង្គម។តំបន់ទេសចរណ៍អាទិភាពត្រូវបានកំណត់ ដូចខាងក្រោម៖

១. តំបន់ទេសចរណ៍វប្បធម៌សៀមរាបអង្គរ តភ្ជាប់ទៅតំបន់បឹងមាលាប្រាសាទព្រះវិហារ និង ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង បឹងទន្លេសាបនិងតំបន់ជុំវិញ។

២. ភ្នំពេញ(និងតំបន់ជុំវិញ)ដែលជារាជធានីដ៏ល្បីល្បាញមួយនៅអាស៊ីអាគ្នេយ៍និងជាមជ្ឈមណ្ឌល នយោបាយ វប្បធម៌ ពាណិជ្ជកម្ម ទេសចរណ៍ ពិសេសទីតាំងប្រសព្វនៃទន្លេមេគង្គបែកជាមុខបួន និងសក្តា នុពលទេសចរណ៍។

៣. ប្រកបរបៀងទេសចរណ៍ភាគខាងត្បូង(តំបន់ឆ្នេរ) ជាតំបន់មានសក្តានុពលអេកូទេសចរណ៍ និង មានភាពទាក់ទាញខ្លាំង ពិសេសការតភ្ជាប់ជាមួយតំបន់អង្គរ ភ្នំពេញ ប្រទេសវៀតណាម និង ប្រទេសថៃ។ តំបន់នេះបញ្ចូលផងដែរនូវតំបន់ភ្នំក្រវាញដ៏មានឥទ្ធិពលនៃជីវៈចម្រុះ ដែលជាមូលដ្ឋានសម្រាប់អេកូទេសចរណ៍។ ។

៤. ភូមិភាគឦសាន ជាតំបន់អេកូទេសចរណ៍ ដែលរំលេចដោយភាពទោល ពិសេសសត្វផ្សោតទន្លេមេគង្គ ទេសភាពធម្មជាតិជីវៈចម្រុះ និងវប្បធម៌ប្រពៃណីរបស់ជនជាតិដើមភាគតិច។

៥. តំបន់ជុំវិញបឹងទន្លេសាប ដែលមានសក្តានុពលអេកូទេសចរណ៍ភ្ជាប់ដោយវប្បធម៌ប្រពៃណីនៃការរស់នៅរបស់ប្រជាជន ពិសេសការងារកសិកម្ម ការនេសាទ និងសិប្បកម្មប្រពៃណី។

៦. តំបន់តាមដងទន្លេមេគង្គភ្ជាប់បឹងទន្លេសាប ទន្លេបាសាក់ដែលមានសក្តានុពលអេកូទេសចរណ៍ និងវប្បធម៌ ពិសេសភាពទាក់ទាញនៃការទស្សនាតាមផ្លូវទឹក។

តំបន់ទាំងនេះមានសក្តានុពលទេសចរណ៍ច្រើនប្រភេទចម្រុះគ្នារួមមានវប្បធម៌ ធម្មជាតិ ប្រវត្តិសាស្ត្រ ការកម្សាន្តតាមបែបផ្សងព្រេង និងផលិតផលថ្មីៗដែលបានបង្កើតឡើង ដែលទាំងអស់នេះ មានភាពទាក់ទាញយ៉ាងខ្លាំងសម្រាប់ទីផ្សារទេសចរណ៍ទាំងក្នុងស្រុកនិងអន្តរជាតិ។

ជាយុទ្ធសាស្ត្រ ការអភិវឌ្ឍផលិតផលទេសចរណ៍ មិនអាចកាត់ផ្តាច់ពីការសិក្សាទីផ្សារ និងសភាពការណ៍និន្នាការទេសចរណ៍តំបន់និងអន្តរជាតិបានទេ។ ការអភិវឌ្ឍផលិតផលត្រូវឱ្យស្របតាមនិន្នាការទីផ្សារ ប៉ុន្តែមិនត្រូវបេត់ឬរត់តាមតម្រូវការទីផ្សារទាំងស្រុងទេព្រោះថា តម្រូវការទីផ្សារខ្លះអាចប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចសង្គមកម្ពុជា។

កម្ពុជាមានសក្តានុពលធំធេងណាស់សម្រាប់ការអភិវឌ្ឍទេសចរណ៍"វប្បធម៌និងធម្មជាតិ"។ បើគិតត្រឹមតែប្រាង្គប្រាសាទបុរាណ កម្ពុជាជាប្រទេសតែមួយគត់ក្នុងអាស៊ី ដែលមានប្រាង្គប្រាសាទបុរាណជាង ១០០០ដែលមានអាយុកាលរាប់ពាន់ឆ្នាំ មិនទាន់គិតអំពីទីតាំង (ទីទួល) និងគ្រឹះប្រាសាទរាប់ពាន់កន្លែងផ្សេងទៀត ដែលសក្តិសមនឹងកិត្តិនាម " ព្រះរាជាណាចក្រនៃវប្បធម៌ "។ កេរដំណែលប្រវត្តិសាស្ត្រ ជាទីគោរពសក្ការៈទាំងនេះប្រមាណតែជិត១០%ប៉ុណ្ណោះដែលត្រូវបានប្រែក្លាយជាគោលដៅទេសចរណ៍។ រីឯ៩០%ទៀតនៃតំបន់ប្រាសាទបុរាណជាច្រើននៅកប់បាត់ឆ្ងាយពីការអភិវឌ្ឍ នៅឡើយ ហើយភាគច្រើននៃតំបន់ប្រាង្គប្រាសាទទាំងនេះមានប្រជាជនរស់នៅដែលភាគច្រើនជាអ្នកក្រីក្រ។ ដូច្នេះការអភិវឌ្ឍតំបន់

ប្រាសាទទាំងនេះឱ្យទៅជាគោលដៅទេសចរណ៍ គឺរួមចំណែកអភិរក្ស ប្រាសាទផង ការអនុញ្ញាតប្រជាជនចូលរួមអភិវឌ្ឍ អភិរក្ស និងការកាត់បន្ថយភាពក្រីក្រផងដែរ។ ម្យ៉ាងវិញ ទៀតតំបន់អេកូទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាគឺជាកំណប់ទ្រព្យដ៏មហាសាលដែលសម្បូរទៅដោយធនធានធម្មជាតិ និងជីវចម្រុះដ៏សម្បូរបែប ពិសេសប្រមូលផ្តុំនៅតាមតំបន់ការពារធម្មជាតិចំនួន ៥៧ កន្លែងស្មើនឹងផ្ទៃដី៧ ៤៣៩ ៦៥៩ ហិកតា (ឧទ្យានជាតិចំនួន១២កន្លែង ដែនជម្រកសត្វព្រៃ១៨កន្លែង តំបន់បេតិកភណ្ឌធម្មជាតិចំនួន០២កន្លែង និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ចំនួន០៣កន្លែង) តំបន់ការពារព្រៃឈើចំនួន០៩កន្លែង ព្រៃកោងកាងដែលផ្សារភ្ជាប់ជាមួយ នឹងការត ភ្ជាប់ទៅនឹងអ័ក្សអេកូឡូស៊ីដ៏ធំនៅលើពិភពលោក គឺព្រៃត្រូពិចជួរភ្នំក្រវ៉ាញដែលមានវិសាលភាពដ៏ធំធេង និងសម្បូរទៅដោយពពួកសត្វកម្រចុងក្រោយនៅតំបន់អាស៊ី ហើយបច្ចុប្បន្ននេះត្រូវបានដាក់បញ្ចូលទៅ ក្នុងតំបន់អេកូទេសចរណ៍ល្បីៗទាំង១០ ក្នុងពិភពលោក។ រីឯតំបន់ឆ្នេរសមុទ្រកម្ពុជាដែលលាតសន្ធឹង ប្រវែង៤៤០គីឡូម៉ែត្រ បានក្លាយជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតជាងគេបំផុតលើសកលលោកតាំងពីឆ្នាំ២០១១មក ហើយសម្បូរទៅដោយរុក្ខជាតិសត្វសមុទ្រ និងជីវចម្រុះជាច្រើនដែលមានប្រមាណ៣០ប្រភេទ ពិសេសព្រៃកោងកាងធំជាងគេនៅអាស៊ីអាគ្នេយ៍គ្របដណ្តប់លើផ្ទៃដី៥០០០០ហិកតា និងផ្កាថ្ម៧០ប្រភេទស្ថិតក្នុង ៣៣ពួកនិង ១១អំបូរ។ លើសពីនេះទៅទៀតតំបន់ភូមិភាគឦសានក៏មានសក្តានុពលដ៏ធំធេងជាមួយតំបន់ខ្ពង់រាប ឧទ្យានជាតិ ទេសភាពទន្លេមេគង្គ សមុទ្រឈើ ទឹកជ្រោះ សត្វផ្សោត ទន្លេមេគង្គ ពពួកសត្វកម្រ និងជីវៈចម្រុះផ្សេងៗទៀត ពិសេសសហគមន៍ជនជាតិភាគតិចច្រើនអំបូរ។ ទាំងអស់នេះគឺជាធនធានអេកូទេសចរណ៍ដែល យើងមិនទាន់ទាញយកមកប្រើប្រាស់ដើម្បីបម្រើក្នុងវិស័យទេសចរណ៍អោយអស់ពីលទ្ធភាព ហើយប្រជាពលរដ្ឋនៅតាមតំបន់អេកូទេសចរណ៍ទាំងនោះនៅមានកម្រិតជីវភាពខ្សត់ខ្សោយនៅឡើយ ហើយការថែរក្សាអភិរក្សធនធានធម្មជាតិទាំងនោះក៏មិនទាន់បានគ្រប់ជ្រុងជ្រោយផងដែរ។

ការបង្កើតផលិតផលថ្មី គឺជាកត្តាចាំបាច់ដើម្បីគាំទ្រផង និងដោះស្រាយផងជាមួយនឹងផលិតផលដែលមានស្រាប់ ព្រមទាំងបំពេញយុទ្ធសាស្ត្រស្តីពីការផ្តល់ជម្រើសឱកាសទស្សនារបស់ ភ្ញៀវឱ្យបានច្រើន និងការពន្យារពេលស្នាក់នៅ ការចំណាយរបស់ភ្ញៀវដើម្បីជំរុញកំណើនការងារ និងសេដ្ឋកិច្ចកម្ពុជា។ ការពឹងផ្អែកតែភាពល្បីល្បាញនៃតំបន់អង្គរឬរាជធានីភ្នំពេញមួយមុខ គឺមិនគ្រប់គ្រាន់ឡើយដើម្បីឈានទៅសម្រេចចក្ខុវិស័យឆ្នាំ២០២០ក្នុងបរិមាណភ្ញៀវ៧លាននាក់។ តំបន់អង្គរដែលមានទេសចរប្រមាណជាង២លាននាក់ទស្សនាក្នុងមួយឆ្នាំៗកាន់តែមានសម្ពាធខ្លាំងឡើងៗទាំងផ្នែកបរិស្ថាននិងវប្បធម៌ ហើយរយៈពេលស្នាក់នៅរបស់ភ្ញៀវក៏មិនបានយូរប៉ុន្មានឡើយ។

ទោះជាយ៉ាងណាក៏ដោយ ក៏អង្គរនៅតែជាប៉ូលទាក់ទាញឬមេដែកធក់ដែលមានកម្លាំងខ្លាំង មិនគ្រាន់តែសម្រាប់កម្ពុជាប៉ុណ្ណោះទេ គឺសម្រាប់តំបន់ទាំងមូលដែលបាននិងកំពុងទទួលផលប្រយោជន៍ពីសក្តានុពលអង្គរនេះ។

## ក. អង្គរនិងតំបន់ជុំវិញ

ការអភិវឌ្ឍផលិតផលទេសចរណ៍គោលដៅទេសចរណ៍ថ្មីៗ នៅជុំវិញអង្គរឬតភ្ជាប់ជាមួយអង្គរ គឺផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចសង្គមយូរអង្វែង និងជាការសម្រាលបន្ទុកកាន់តែធូរនៅតំបន់បេតិកភណ្ឌអង្គរ។ ជាក់ស្តែងការអភិវឌ្ឍគោលដៅទេសចរណ៍ "ចុងឃ្នាស" និងផ្នែកខ្លះនៃបឹងទន្លេសាប បច្ចុប្បន្ន បានផ្តល់ផ្លែផ្កាយ៉ាងសំខាន់ដល់គ្រប់ផ្នែកពាក់ព័ន្ធ រួមមានប្រជាជន ពិសេសសហគមន៍ទូក កាណូត ដឹកភ្ញៀវទេសចរកម្សាន្ត និងសេវាកម្មនានានៅទីនោះ។ តាមការសិក្សាប្រមាណ ជា៤០%នៃភ្ញៀវមកសៀមរាប អង្គរ បានទៅទស្សនាបឹងទន្លេសាប។ ក្រៅពីចុងឃ្នាសក៏នៅមានតំបន់ ជាច្រើននៅជុំវិញបឹងទន្លេសាបបាន និងកំពុងរៀបចំជាសហគមន៍ទេសចរណ៍ គោលដៅទេសចរណ៍ ដើម្បីទាក់ទាញការទស្សនារបស់ភ្ញៀវ ដូចជា នៅកំពង់ភ្លុក កំពង់ឃ្លាំង ព្រែកទាល់ មេជ្រៃ ជាដើម។

ការតភ្ជាប់អង្គរជាមួយតំបន់ផ្សេងៗត្រូវធ្វើឡើងទាំងប្រាំទិស (ដូចកំពូលប្រាសាទអង្គរជាតំណាង) ហើយត្រូវភ្ជាប់ដោយគ្រប់មធ្យោបាយដឹកជញ្ជូនទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធសមស្រប។ ទិសនៃការតភ្ជាប់សំខាន់ៗរួមមានភាគខាងត្បូង អង្គរភ្ជាប់ជាមួយបឹងទន្លេសាប និងតំបន់ជុំវិញរហូតដល់តំបន់សំខាន់ៗនៃខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងតភ្ជាប់តាមផ្លូវអាកាសជាមួយខេត្តព្រះសីហនុនិងតំបន់ឆ្នេរទាំងមូល។ ភាគខាងជើងតភ្ជាប់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ជួរភ្នំដងរែក ពិសេសប្រាសាទព្រះវិហារ(បេតិកភណ្ឌពិភពលោក) ជាទីសក្ការៈដ៏មានឥទ្ធិពល ភូមិតេជោ ហើយបន្តភ្ជាប់ជាមួយប្រាសាទវត្តភូ តាមផ្លូវបុរាណកាត់ខេត្តព្រះវិហារ និងមួយផ្នែកតភ្ជាប់ជាមួយខេត្ត ស្ទឹងត្រែង និងភូមិភាគឦសានទាំងមូលដែលសម្បូរទៅដោយធនធានធម្មជាតិនិងវប្បធម៌ រួមមានជនជាតិដើមភាគតិចតំបន់ភ្នំ។ ឆ្ពោះមកទិសខាងកើតតាមផ្លូវជាតិលេខ៦ភ្ជាប់មកខេត្តកំពង់ធំ ដែលជាខេត្តភាគកណ្តាលដ៏ធំ និងមានសក្តានុពលទាំងវប្បធម៌និងធម្មជាតិ ក្នុងនោះប្រាសាទសំបូរព្រៃគុកដែលទើបតែចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីថ្ងៃទី០៨ខែកក្កដាឆ្នាំ២០១៧កំពុងទាក់ទាញទេសចរយ៉ាងខ្លាំងក្លា។

តាមទិសនេះអង្គរក៏តភ្ជាប់ជាមួយខេត្តកំពង់ចាម ខេត្តកណ្តាល និងពិសេសរាជធានីភ្នំពេញដែលជាបេះដូង នៃកម្ពុជា។ ភាគខាងលិចតំបន់អង្គរក៏មានសក្តានុពលខ្លាំងផងដែរ គឺនៅក្នុងខេត្តឧត្តមានជ័យ និងខេត្ត បន្ទាយមានជ័យ ដែលមានសក្តានុពលសម្បត្តិធម្មជាតិនិងធនធានវប្បធម៌ ដូចជាអាងត្រពាំងថ្ម និងប្រាសាទបុរាណ ស្ពានបុរាណ ពិសេសនៅតាមផ្លូវជ័យវរ្ម័នទី៧ តភ្ជាប់អង្គរទៅកាន់ប្រាសាទបុរាណខ្មែរនៅក្នុងទឹកដីថៃបច្ចុប្បន្ន។ អង្គរបាននិងកំពុងតភ្ជាប់យ៉ាងសកម្មជាមួយតំបន់ និងពិភពលោកតាមគ្រប់មធ្យោបាយ ផ្លូវទឹកផ្លូវគោកនិងផ្លូវអាកាស ក្រោមគោលនយោបាយ "បើកចំហជើងមេឃ" របស់រាជរដ្ឋាភិបាល។ ប្រទេសជាច្រើនក្នុងតំបន់កំពុងទទួលផលពីសក្តានុពល "ទោល" របស់អង្គរដោយភ្ជាប់អង្គរដោយ

ត្រង់ជាមួយប្រទេសទាំងនោះ ក្នុងនោះមួយផ្នែកភ្ជាប់ជាមួយតំបន់ឆ្នេរដែលមានសក្តានុពលធម្មជាតិ ដូចជាការហោះហើរត្រង់ភ្ជាប់អង្គរជាមួយកោះសាមុយ(ថៃ) សិង្ហបុរី និងតំបន់ឆ្នេររបស់វៀតណាម។ល។

រាជរដ្ឋាភិបាលយកចិត្តទុកដាក់ខ្ពស់ក្នុងការដាក់ចេញនិងបន្តអនុវត្តនូវគោលនយោបាយបើកចំហជើងមេឃ ផ្លូវអាកាស ផ្លូវគោក ផ្លូវទឹក និងយុទ្ធសាស្ត្រ "អង្គរជាប៉ូលអាទិភាព" ដើម្បីជួយគាំទ្រការអភិវឌ្ឍទេសចរណ៍កម្ពុជា។ ជាងនេះទៀត រាជរដ្ឋាភិបាលបន្តយ៉ាងសកម្មដោយសហការជាមួយដៃគូអភិវឌ្ឍ និងផ្នែកឯកជន និងការចូលរួមរបស់ប្រជាជនក្នុងការអភិវឌ្ឍគោលដៅទេសចរណ៍ ផលិតផលទេសចរណ៍នៅជុំវិញឬតភ្ជាប់ជាមួយអង្គរដើម្បីគោលដៅចម្បង គឺការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធានដែលមានប្រកបដោយការទទួលខុសត្រូវ ដើម្បីអភិវឌ្ឍទេសចរណ៍ រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ គ្រប់ទីកន្លែងដែលមានសក្តានុពលទេសចរណ៍ទាំងវប្បធម៌និងធម្មជាតិត្រូវយកចិត្តទុកដាក់រៀបចំប្រែក្លាយជាគោលដៅទេសចរណ៍ និងផ្សព្វផ្សាយទាក់ទាញទេសចរទៅទស្សនា និងរៀបចំយន្តការគ្រប់គ្រងអភិវឌ្ឍនៅនឹងកន្លែង ក្នុងនោះការប្រមូលផ្តុំ ចងក្រងជាសហគមន៍ទេសចរណ៍ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ជូនប្រជាជនមូលដ្ឋានគឺជាអាទិភាព។

ការយកចិត្តទុកដាក់បង្កលក្ខណៈងាយស្រួលជូនប្រជាជន ដោយជំរុញលើកទឹកចិត្ត បណ្តុះគំនិតផ្តួចផ្តើមបង្កើត ឬច្នៃប្រឌិតបង្កើតឱ្យចេញជាផលិតផលទេសចរណ៍ថ្មីៗឈរលើមូលដ្ឋាន ធនធានដែលមាន ស្រាប់ដូចជា៖

ផលិតនិងចលនាលក់វត្ថុសិប្បកម្ម ជាលក្ខណៈវត្ថុអនុស្សាវរីយ៍ទេសចរណ៍ ដែលបង្ហាញនូវវប្បធម៌និងប្រពៃណីរស់នៅរបស់ប្រជាជនតាមតំបន់ផ្សេងៗគ្នា។ ការបង្ហាញសិល្បៈ របាំ ចម្រៀងប្រពៃណី ម្ហូបអាហារផ្លែឈើជាដើម ជូនទេសចរនៅតាមសហគមន៍នានា។ ការបង្ហាញឬការអនុញ្ញាតឱ្យទេសចរចូលរួមសកម្មភាពសមស្រប អំពីជីវភាពរស់នៅពិតៗរបស់ប្រជាជនតាមសហគមន៍រួមមាន៖ ការបង្កបង្កើនផលការនេសាទត្រី និងការប្រារព្ធពិធីបុណ្យទានជំនឿសាសនា។ល។ ដើម្បីឱ្យទេសចរបានស្គាល់និង រីករាយចូលរួម។ ករណីនេះផ្សារភ្ជាប់ជាមួយ "ទេសចរណ៍ជនបទ" ដែលកំពុងទទួលជោគជ័យនៅស្រុកបារាយណ៍ខេត្តកំពង់ធំ។ ទេសចរណ៍រួមវិភាគទានដល់ការអភិវឌ្ឍ ដូចជាការលើកទឹកចិត្ត ឱ្យទេសចរចូលរួមដាំដើមឈើ "ទេសចរម្នាក់ ដើមឈើមួយដើម" ឬ "ដើមឈើមួយដើម ផ្តើមចេញពីអ្នក" ជីកអណ្តូងទឹក សាងសង់ផ្ទះ សាលារៀន មន្ទីរពេទ្យ ឬការចូលរួមជួយផ្តល់អំណោយមនុស្សធម៌នានា។ បំផុសចលនាប្រជាជនឱ្យផលិត ផលិតផលនានា ដើម្បីលក់បម្រើឱ្យទីផ្សារទេសចរណ៍ ដូចជា បន្លែ ផ្លែឈើ ផ្កា ត្រីសាច់ គ្រឿងសង្ហារឹម ដែលតម្រូវការនេះកើនឡើងជាប្រចាំតាមកំណើនទេសចរ ហើយបច្ចុប្បន្ន មួយផ្នែកត្រូវបាននាំចូលពីបរទេស។ ការបង្កើនការផ្គត់ផ្គង់ក្នុងស្រុកគឺកាត់បន្ថយការនាំចូល និងទប់ស្កាត់ការឆ្លុះឆ្លាយសេដ្ឋកិច្ច និងជំរុញសកម្មភាពសហគ្រាស ធុនតូចនិងមធ្យម(SME)។

សកម្មភាពនិងលទ្ធផលខាងលើនេះ គឺសំខាន់ជំរុញការអភិវឌ្ឍទេសចរណ៍ផង និងការជួយកាត់បន្ថយភាពក្រីក្រតាមរយៈទេសចរណ៍ផង ដែលនេះគឺជាគោលដៅចម្បងរបស់រាជរដ្ឋាភិបាលដោយស្របតាម យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា។




(រូបភាព: អង្គរ និងតំបន់ជុំវិញ)

## ខ. ភ្នំពេញនិងតំបន់ជុំវិញ

រាជធានីភ្នំពេញ គឺជាបេះដូងនិងជាមជ្ឈមណ្ឌលនយោបាយពាណិជ្ជកម្ម វប្បធម៌ និងទេសចរណ៍នៃកម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ។ ភ្នំពេញជារាជធានីដ៏ចំណាស់មួយនៅអាស៊ី និងមានទីតាំងជាយុទ្ធ

សាស្ត្រនៅចំណុចប្រសព្វបួនមុខនៃទន្លេមេគង្គ។ រាជធានីភ្នំពេញដែលទទួលបានមេដាយពិភពលោកបាន ប្រែក្លាយពីទីក្រុង "សូន្យ" ខ្ទេចខ្ទាំដោយសារសង្គ្រាមនិងរបបប្រល័យពូជសាសន៍ ទៅជារាជធានីកំពុង អភិវឌ្ឍលើគ្រប់វិស័យ។ ភ្នំពេញតភ្ជាប់ជាមួយពិភពលោកតាមគ្រប់មធ្យោបាយដឹកជញ្ជូនទេសចរទាំងផ្លូវ គោក ផ្លូវទឹក និងផ្លូវអាកាស ក្នុងនោះព្រលានយន្តហោះអន្តរជាតិភ្នំពេញកំពុងបំពេញតួនាទីជាស្នូលយ៉ាង សកម្ម ដោយមានសមត្ថភាពទទួលអ្នកដំណើរបានជាងមួយលាននាក់ក្នុងមួយឆ្នាំៗ។

រាជធានីភ្នំពេញ ជាមជ្ឈមណ្ឌលប្រមូលផ្តុំនូវរតនសម្បត្តិបេតិកភណ្ឌវប្បធម៌ជាច្រើនដែលជាប្រភព ធនធានដ៏សំខាន់សម្រាប់ការទាក់ទាញទេសចរ ដូចជាសារមន្ទីរជាតិ ព្រះបរមរាជវាំង ទីតាំងប្រវត្តិសាស្ត្រ វត្តភ្នំ និងសំណង់ស្ថាបត្យកម្មសម័យអាណានិគម។ល។ ជាងនេះទៅទៀតរាជធានីភ្នំពេញ សម័យតេជោ មានការអភិវឌ្ឍបានរំលេចនូវសំណង់អគារថ្មីខ្ពស់ៗ សណ្ឋាគារល្អប្រណីតលំដាប់អន្តរជាតិ និងសេវាកម្ម ទេសចរណ៍ច្រើនប្រភេទ អមដោយភាពស្រស់ស្អាតនៃការតុបតែងលម្អនានា នាំឱ្យទីក្រុងនេះ ក្លាយជា គោលដៅទេសចរណ៍ជាទីពេញនិយម។ នៅជុំវិញរាជធានីក៏មានសក្តានុពលទាក់ទាញទេសចរ វប្បធម៌និង ធម្មជាតិ ដោយភ្ជាប់ពីលក្ខណៈទេសចរណ៍ "ទីក្រុង" ទៅទេសចរណ៍ "ជនបទ" និងកសិទេសចរណ៍ ពិសេសសម្រាប់អ្នករស់នៅក្នុងទីក្រុងនិងភ្ញៀវបរទេស។ គោលដៅទេសចរណ៍តំបន់ជុំវិញ បាននិងកំពុង អភិវឌ្ឍរួមមាន ភ្នំព្រះរាជទ្រព្យ (ភ្នំឧត្តុង្គ) ភ្នំប្រសិទ្ធិ កោះដាច់ តំបន់ភាគខាងកើតរាជធានីភ្នំពេញ និងការ តភ្ជាប់ជាមួយតំបន់ផ្សេងៗទៀតនៃខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ដូចជា ទន្លេបាទី។ល។ តំបន់កប់ស្រូវគួរត្រូវរៀបចំអភិវឌ្ឍទៅជាតំបន់សម្រាកកម្សាន្ត នៅក្នុងរាជធានីភ្នំពេញ តែម្តង។

រាជធានីភ្នំពេញកាន់តែមានកំណើនប្រជាជន និងមធ្យោបាយដឹកជញ្ជូនច្រើនឡើង ដែលរួមមាន ប្រជាជនប្រមាណ២លាននាក់ទេសចរជាតិនិងអន្តរជាតិជាង២លាននាក់ក្នុងមួយឆ្នាំ និងមធ្យោបាយដឹក ជញ្ជូនជាងមួយលានគ្រឿង។ កត្តានេះបង្កជាចលករ"រុញ"នៃចរន្តទេសចរណ៍ផ្ទៃក្នុងកាន់តែខ្លាំងឡើងៗ។ ដោយសារនិន្នាការនេះការជំរុញការអភិវឌ្ឍផលិតផលទេសចរណ៍នៅក្នុង និង តំបន់ជុំវិញរាជធានីភ្នំពេញ គឺជាការចាំបាច់និងបន្ទាន់ដើម្បីការផ្គត់ផ្គង់តម្រូវការទេសចរផង និងស្រូបយកផលទេសចរណ៍សម្រាប់ ប្រជាជនផង។

រាជធានីភ្នំពេញនិងតំបន់ជុំវិញនៅមានសក្តានុពលច្រើនសម្រាប់ការអភិវឌ្ឍទេសចរណ៍ដើម្បី ពន្យារការស្នាក់នៅរបស់ភ្ញៀវបានយូរ ដូចជា ការទស្សនាកម្សាន្តតាមនាវាតាមដងទន្លេមេគង្គ (ទន្លេសាប) ការទស្សនាសហគមន៍ប្រជាជននៅតាមដងទន្លេ ភូមិសិប្បកម្មតម្បាញ ចម្លាក់ប្រាក់ តំបន់កសិទេសចរណ៍ និងតំបន់បេតិកភណ្ឌវប្បធម៌ ការកម្សាន្តនៅពេលរាត្រីតាមដងទន្លេចតុមុខ ផ្សាររាត្រី ការរៀបចំតំបន់ ទេសចរណ៍ពេលរាត្រីប្រកបដោយសុវត្ថិភាព និងការទស្សនាមណ្ឌលពាណិជ្ជកម្ម និងផ្សារលក់ដូរ។ល។

រាជធានីភ្នំពេញ បច្ចុប្បន្នត្រូវបានពង្រីកវិសាលភាពយ៉ាងធំធេង ដែលស័ក្តិសមជារាជធានីសម័យ តេជោដោយរួមមាន ទីក្រុងរណបលំដាប់ពិភពលោកជាច្រើនកំពុងត្រូវបានស្ថាបនាឡើងតភ្ជាប់ដោយ

ប្រព័ន្ធសមស្រប។ ទីក្រុងរណបទាំងនេះក្លាយជាលំនៅឋានផង និងជាផលិតផលទេសចរណ៍សម្រាប់រាជធានីផង។ ក្រៅពីនេះតំបន់ជាយរាជធានីភ្នំពេញ ដូចជាតំបន់កប់ស្រូវនិងតាមដងទន្លេមានសក្តានុពលទាក់ទាញបែបអេកូទេសចរណ៍ អាចរៀបចំជាតំបន់សម្រាកលំហែកម្សាន្ត សម្រាប់ទាំងភ្ញៀវនិងអ្នករស់នៅក្នុងរាជធានីដែលកាន់តែច្រើនឡើងៗ។ ម្យ៉ាងទៀត ផលិតផលផ្នែកសេវាកម្សាន្តទេសចរណ៍ ត្រូវយកចិត្តទុកដាក់ពង្រឹងនិងពង្រីកឱ្យបានកាន់តែប្រសើរនិងសមស្រប ដើម្បីលើកកម្ពស់ រាជធានីភ្នំពេញឱ្យក្លាយជារាជធានីមានសកម្មភាពរស់រវើក ស្របតាមស្តង់ដាទីក្រុងស្អាត សំដៅទាក់ទាញទេសចរណ៍ផង និងបង្កើនការងារទេសចរណ៍ផង។

ទោះជាយ៉ាងណាក៏ដោយ ក៏ភ្នំពេញត្រូវអភិវឌ្ឍស្របតាមប្លង់មេនៃការអភិវឌ្ឍទីក្រុងយ៉ាងពិតប្រាកដ ដោយប្រែក្លាយទៅជា "គុជ" មួយនៅអាស៊ី ទាំងភាពស្អាត ទាំងភាពបៃតង និងទាំងសណ្តាប់ធ្នាប់របៀបរៀបរយ។ ភ្នំពេញត្រៀមលក្ខណសម្បត្តិគ្រប់យ៉ាងដើម្បីធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំវេទិកា និងសន្និសីទ កម្រិតអន្តរជាតិជាច្រើន ហើយនិងត្រៀមទទួលភ្ញៀវទេសចរអន្តរជាតិប្រមាណបីលាននាក់ក្នុងមួយឆ្នាំៗ ចាប់ពី២០១៣ ដោយមិនទាន់គិតភ្ញៀវទេសចរក្នុងស្រុកជាច្រើនលាននាក់ចូលមករាជធានីជារៀងរាល់ឆ្នាំ។ ភ្នំពេញទាមទារនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្បទាទេសចរណ៍ជាច្រើនទៀត ដើម្បីស្រូបយកកំណើននេះ ពិសេសផ្លូវព្រលានយន្តហោះ ការផ្គត់ផ្គង់ទឹកស្អាត និងថាមពលអគ្គិសនី។ រាជធានីភ្នំពេញចាំបាច់ត្រូវមានព្រលានយន្តហោះខ្នាតធំកម្រិតអន្តរជាតិដើម្បីធ្វើជាស្នូលក្នុងការតភ្ជាប់ពិភពលោក។ ព្រលានយន្តហោះខ្នាតធំដែលមានសមត្ថភាពផ្ទុកប្រមាណ១០លាននាក់ក្នុងមួយឆ្នាំ នឹងដើរតួនាទីជាគន្លឹះក្នុងការរំដោះកម្ពុជាចេញពីភាពជា"គោលដៅទេសចរណ៍រណប" ដូចដែលធ្លាប់បាននិងកំពុងជួបប្រទះកន្លងមក និងពេលបច្ចុប្បន្នទៅជាគោលដៅទេសចរណ៍ទី១សម្រាប់ពិភពលោក។ ដូច្នេះការរៀបចំផែនការសិក្សាអំពីព្រលានយន្តហោះនេះ ត្រូវចាប់ផ្តើមពីពេលនេះទៅ ហើយបើខកខាននោះកម្ពុជា នឹងបាត់បង់ឱកាសបន្តទៀត។



(រូបថតៈ រាជធានីភ្នំពេញ)

**គ. ការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរ**

តំបន់ឆ្នេរដែលស្ថិតក្នុងច្រករបៀងទេសចរណ៍ភាគខាងត្បូង ជាតារារះនាទិសនិរតីរួមបញ្ចូល ខេត្ត ៤គឺ ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុង ដែលបាននិងកំពុងក្លាយជាប៉ូលដ៏សំខាន់ សម្រាប់ស្រូបទាញទេសចរជាតិនិងអន្តរជាតិ។ ឆ្នេរសមុទ្រកម្ពុជាត្រូវបានក្លាយជាសមាជិកនៃក្លឹប ឆ្នេរស មុទ្រដ៏ស្អាតបំផុតលើសកលលោក ហើយកិត្តិនាមនេះកំពុងលើកតម្កើងកិត្យានុភាពឆ្នេរកម្ពុជាលើ ឆាក អន្តរជាតិ។ តំបន់ឆ្នេរកម្ពុជាមានធនធានចម្រុះ សម្បូរ និងច្រើនប្រភេទសម្រាប់ការអភិវឌ្ឍទេសចរណ៍ ហើយធនធានទាំងនេះនៅថ្មី និងមានភាពទាក់ទាញយ៉ាងខ្លាំង។ តំបន់ឆ្នេរស្ថិតក្នុងក្របខ័ណ្ឌនៃកិច្ចសហ ប្រតិបត្តិការនៃច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ដែលភ្ជាប់ប្រទេសវៀតណាម និងប្រទេសថៃ ដោយ គមនាគមន៍ផ្លូវគោក(ផ្លូវលេខ៣៣ ផ្លូវលេខ៣ និងផ្លូវលេខ៤៨) និងផ្លូវទឹកយ៉ាងល្អប្រសើរក្នុងពេល បច្ចុប្បន្ន ហើយអនាគតនឹងមានការតភ្ជាប់តាមផ្លូវអាកាសជាលក្ខណៈអន្តរជាតិ។ តំបន់នេះស្ថិតនៅ មិន ឆ្ងាយពីប៉ូលអង្គរដ៏ខ្លាំង ដែលមានទេសចរប្រមាណជាង២លាននាក់ក្នុងមួយឆ្នាំនិងនៅជិតរាជធានី ភ្នំពេញ ដែលមានទាំងទេសចរទាំងប្រជាជនដែលរស់នៅប្រមាណជិតបីលាននាក់ រួមទាំងធុរជននិង បុគ្គលិក

បម្រើតាមស្ថាប័នអង្គការអន្តរជាតិនានា។ តំបន់ឆ្នេរក៏ភ្ជាប់ជាមួយរាជធានីភ្នំពេញដោយបណ្តាញ ផ្លូវដែក ដែលនឹងក្លាយជាមធ្យោបាយដឹកជញ្ជូនទេសចរដ៏សំខាន់មួយក្នុងថ្ងៃអនាគត។ រាជរដ្ឋាភិបាល ប្តេជ្ញាចិត្ត បន្តជំរុញការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរប្រកបដោយការទទួល ខុសត្រូវដើម្បីបង្កើត និងអភិវឌ្ឍ ផលិតផលទេសចរណ៍ ផ្តល់ជម្រើសថ្មីៗជូនទេសចរ និងគាំទ្រការតភ្ជាប់ តំបន់ឆ្នេរជាមួយទេសចរណ៍ វប្បធម៌អង្គរ និងតំបន់នានាដើម្បីផ្តល់ផលប្រយោជន៍ទេសចរណ៍ប្រកបដោយសមធម៌នៅតំបន់ឆ្នេរផង និងទូទាំងប្រទេសផង។ តំបន់ឆ្នេរពិសេសខេត្តព្រះសីហនុ គឺជាក្បាលនាគរីឯខ្លួននិងកន្ទុយ គឺរាជធានី ភ្នំពេញ និងភូមិភាគឦសាន។

ការតភ្ជាប់ជាមួយប្រទេសវៀតណាមភាគខាងត្បូង គឺជាយុទ្ធសាស្ត្រគន្លឹះសំខាន់មួយ ទៀតក្នុងការជំរុញគាំទ្រការលេចត្រដែតឡើងនៃតំបន់ឆ្នេរកម្ពុជា ពិសេសការភ្ជាប់ខេត្តកែប ខេត្តកំពត (មានភ្នំបូកគោដែលបានក្លាយជាគោលដៅទេសចរណ៍ដ៏ល្បីល្បាញ) ជាមួយដែនដីសណ្តទន្លេមេគង្គនិង ប្រជុំកោះនានាជាគោលដៅអាទិភាព។ ប្រទេសវៀតណាមបានកំណត់យុទ្ធសាស្ត្រ ដោយចាប់យកប្រជុំកោះ ភាគខាងត្បូងជាប៉ូលទេសចរណ៍ ដែលមានកម្លាំងស្របរហូតដល់ប្រមាណពីរលាននាក់ក្នុងមួយឆ្នាំៗ ចាប់ពីឆ្នាំ ២០១៣។ តំបន់នេះត្រូវបានបើកទូលាយក្នុងការមកទស្សនាដោយអនុវត្តគោលនយោបាយ "គ្មានទិដ្ឋាការ" និងបង្កើតតំបន់កម្សាន្តលំដាប់អន្តរជាតិធំៗ។ ពីតំបន់នេះមកឆ្នេរខេត្តកំពត មានរយៈពេល តែប្រមាណ៤៥នាទីប៉ុណ្ណោះ តាមនាវាទេសចរណ៍លឿន ហើយទំនាញនៃប៉ូលទាំងពីរ "បូកគោ" និង "តំបន់កោះ" និងផ្ទុះចេញជាចរន្តទេសចរណ៍តភ្ជាប់យ៉ាងខ្លាំងនៅពេលខាងមុខ។ បន្ថែមពីនេះដែនដីសណ្ត ទន្លេមេគង្គ រួមទាំងទីក្រុងហូជីមិញដែលមានប្រជាជនសរុបជាង៣០លាននាក់និងភ្ញៀវមកពីប្រភពនានា ទស្សនាភាគខាងត្បូងប្រទេសវៀតណាម គឺជាប្រភពទីផ្សារទេសចរណ៍ដ៏ធំក្នុងតំបន់សម្រាប់ផ្គត់ផ្គង់ភាគ និរតីកម្ពុជា និងកម្ពុជាទាំងមូល។

កត្តាគន្លឹះនៃការអភិវឌ្ឍតំបន់ឆ្នេរនេះ គឺហេដ្ឋារចនាសម្ព័ន្ធក្នុងនោះផ្លូវជាតិលេខ៣ លេខ៤ និងផ្លូវដែកតភ្ជាប់ជាមួយរាជធានីភ្នំពេញបាននិងកំពុងធ្វើឱ្យប្រសើរឡើង។ ការផ្គត់ផ្គង់ថាមពលនិងទឹកស្អាត នឹងមិនចោទជាបញ្ហាឡើយ ដោយសារដំណោះស្រាយដ៏ល្អនៃវារីអគ្គិសនី " ភ្នំកំចាយ " និង ប្រភពថាមពលផ្សេងៗទៀតដែលត្រូវបង្កើតនិងផ្គត់ផ្គង់។ កំពង់ផែនិងព្រលានយន្តហោះខេត្តព្រះសីហនុ មានសមត្ថភាពគ្រប់គ្រាន់កម្រិតអន្តរជាតិនៅថ្ងៃអនាគត។ កត្តាចាំបាច់ដើម្បីបង្កើនល្បឿនអភិវឌ្ឍតំបន់ នេះបន្ថែម គឺការអភិវឌ្ឍផលិតផលទេសចរណ៍ អេកូទេសចរណ៍ និងទេសចរណ៍បែបកម្សាន្ត ផ្សារភ្ជាប់ សក្តានុពលវប្បធម៌ធម្មជាតិ និងប្រវត្តិសាស្ត្រនៃតំបន់នេះពិសេសភ្នំបូកគោនឹងក្លាយជារមណីយដ្ឋាន ទេសចរណ៍ធម្មជាតិទេសចរណ៍កម្សាន្តកម្រិតពិភពលោក។

**ខេត្តព្រះសីហនុ** គឺជាស្នូលនៃតំបន់ឆ្នេរជាច្រកអន្តរជាតិ ជាមជ្ឈមណ្ឌលឧស្សាហកម្ម និង ជាគោលដៅទេសចរណ៍លំដាប់អន្តរជាតិ កំពុងរះឡើងតាមរយៈនៃភាពស្អាតជាលក្ខណៈធម្មជាតិ និងការ រៀបចំ

ព្រមទាំងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរឡើង ពិសេសផ្លូវគមនាគមន៍ ព្រលានយន្តហោះ និង កំពង់ផែអន្តរជាតិ ដែលជាមូលដ្ឋានគ្រឹះក្នុងការតភ្ជាប់ខេត្តព្រះសីហនុនិងតំបន់ឆ្នេរទាំងមូល ជាមួយ តំបន់នានាក្នុងនិងក្រៅប្រទេស។

**ខេត្តកោះកុង** គឺជាគោលដៅអេកូទេសចរណ៍ខ្លាតពិភពលោក ដោយសារសក្តានុពល នៃទីតាំងភូមិសាស្ត្រ ធនធានសមុទ្រ ព្រៃឈើ ព្រៃកោងកាង រួមនឹងការតភ្ជាប់ទៅនឹងអ័ក្សអេកូឡូស៊ីដ៏ធំនៅលើសកលលោក គឺតំបន់ព្រៃត្រពិច ភ្នំក្រវាញដែលមានវិសាលភាពដ៏ធំធេង និងសំបូរទៅដោយ ពពួកសត្វកម្រ និងជាតំបន់ចុងក្រោយនៅតំបន់អាស៊ី ហើយបច្ចុប្បន្នតំបន់នេះត្រូវបានកត់បញ្ចូលទៅក្នុងតំបន់អេកូទេសចរណ៍ល្បីៗទាំង១០នៅក្នុងសកលលោក។ សក្តានុពលអេកូទេសចរណ៍តំបន់ភ្នំ ទេសភាពតាមដងស្ទឹង ការទស្សនាសត្វព្រៃលាយឡំប្រវត្តិសាស្ត្រ ប្រពៃណី ជីវិតរស់នៅរបស់ប្រជាជន និងធនធានធម្មជាតិ សម្រស់ស្ទឹងធម្មជាតិ ឆ្នេរសមុទ្រ និងកោះនានាបាននិងកំពុងលើកកម្ពស់កិត្តិនាមខេត្តកោះកុង ជាខេត្តអេកូទេសចរណ៍តំបន់ឆ្នេរភាគនិរតីនៃកម្ពុជា។ ម្យ៉ាងទៀតខេត្តកោះកុង គឺជាស្ពានតភ្ជាប់តំបន់ឆ្នេរ និងកម្ពុជាទាំងមូល ជាមួយភាគអាគ្នេយ៍ប្រទេសថៃដែលប្រមូលផ្តុំដោយប្រជាជនច្រើន និងមានទេសចរអន្តរជាតិប្រមាណជា៤លាននាក់ទស្សនាក្នុងតំបន់នេះ ហើយក៏តភ្ជាប់ជាមួយទីក្រុងបាងកកដែលជាច្រកចេញចូលនៃទេសចរអន្តរជាតិ ប្រមាណជាង១០លាននាក់ក្នុងមួយឆ្នាំៗ ពិសេសព្រលានយន្តហោះ អន្តរជាតិដែលជាស្នូលភ្ជាប់ជាមួយពិភពលោក។

ភាពចាំបាច់នៃខេត្តកោះកុង គឺការស្តារនិងការអភិវឌ្ឍព្រលានយន្តហោះដែលមានស្រាប់ ឡើងវិញ និងការអភិវឌ្ឍបន្ថែម ឆ្នេរសម្រាកលម្ហែកម្សាន្ត និងការទាក់ទាញការទស្សនាតាមនាវា តាមប្រជុំកោះ និងនៅតាមសហគមន៍អេកូទេសចរណ៍នានាពិសេសតំបន់ព្រៃកោងកាង។ ព្រលានយន្តហោះខេត្តកោះកុងនឹងក្លាយជាស្ពានតភ្ជាប់ខេត្តសៀមរាប រាជធានីភ្នំពេញ និងតំបន់ផ្សេងៗទៀតឬអាចតភ្ជាប់ជាលក្ខណៈ អន្តរជាតិផងដែរនាពេលអនាគត។

**ខេត្តកំពត** ជាមជ្ឈមណ្ឌលកសិកម្ម និងកែច្នៃផលិតផលកសិកម្មដែលមានបច្ចេកវិទ្យាខ្ពស់ ជាមណ្ឌលពាណិជ្ជកម្ម និងសេដ្ឋកិច្ចក្នុងតំបន់ និងអន្តរជាតិ និងជាគោលដៅទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិល្អឯកដោយសក្តានុពលនៃទីតាំងភូមិសាស្ត្រ ធនធានសមុទ្រ បេតិកភណ្ឌ វប្បធម៌ រមណីយដ្ឋានភ្នំបូកគោ ផ្ទៃដីកសិកម្ម និងលក្ខណៈពិសេសនៃផលដំណាំកសិកម្ម មានទុរេន ម្រេច ស្រែអំបិល និងផលនេសាទសមុទ្រ។

**ខេត្តកែប** ជាគោលដៅទេសចរណ៍ សម្រាកលម្ហែសម្រាប់សុខភាព និងជាមជ្ឈមណ្ឌលទាក់ទាញភ្ញៀវទេសចរដែលស្រឡាញ់ធម្មជាតិ។ លក្ខណៈពិសេសទាំងនេះបានធ្វើឱ្យខេត្តទាំងបួននេះ ត្រូវបានធ្វើសមាហរណកម្មទៅជាតំបន់ឆ្នេរសមុទ្រកម្ពុជា ដោយអ័ក្សនៃតំបន់ឆ្នេរតភ្ជាប់ពីខេត្តកោះកុង មកខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប ជាមួយផ្លូវអាស៊ានហាយវេលេខ១២៣ និងតភ្ជាប់មករាជធានីភ្នំពេញតាម

រយៈអ័ក្សភ្នំពេញ ព្រះសីហនុជាមួយផ្លូវហាយវេលេខ១១។ ជាមួយគ្នានេះដែរ យើងក៏សង្កេត ឃើញនូវការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័សខាងផ្នែកនគរូបនីយកម្ម និងសំណង់ ដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន មណ្ឌលកម្សាន្ត រមណីយដ្ឋានជាដើម ដែលបាន រួមចំណែកដល់ការលើក

កម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ឆ្នេរ និងបានគាំទ្រដល់ការរីកលូតលាស់នៃអន្តរ វិស័យដទៃទៀត។ ជារួមការវិនិយោគឯកជនទាំងអស់នេះ កំពុងមានសន្ទុះរីកចម្រើនយ៉ាងខ្លាំងនៅខេត្ត តំបន់ឆ្នេរនេះ។ ការវិនិយោគត្រូវបានអនុម័តចំនួន១១៧គម្រោង ស្មើនឹង១០៧០១លានដុល្លារ ស្មើនឹង ៤១,៦%នៃគម្រោងវិនិយោគសរុបទូទាំងប្រទេស។

ជាយុទ្ធសាស្ត្រកំពង់ផែទេសចរណ៍ខ្នាតអន្តរជាតិមួយចាំបាច់ត្រូវកសាងឡើង នៅខេត្តកំពត ដើម្បីជាច្រកចូលបន្ថែមក្នុងតំបន់ពិសេសភ្ជាប់តំបន់កោះនានា និងភាគខាងត្បូងវៀតណាមជាមួយ "បូកគោ" នៅពេលដែលតំបន់ទាំងនេះភ្ជាប់គ្នា។ ក្រៅពីនេះត្រូវលើកទឹកចិត្តជំរុញការវិនិយោគ ទេសចរណ៍កម្សាន្តតាមនាវាតាមប្រជុំកោះ និងតាមបណ្តោយឆ្នេរ ដោយរួមមានការកសាង រមណីយដ្ឋានទេសចរណ៍ សកម្មភាពកីឡាទេសចរណ៍ (ពិសេសកីឡាកូនហ្គោល) និងប្រភេទទេសចរណ៍កម្សាន្ត សមស្របផ្សេងៗទៀត។ តំបន់នេះក៏មានសក្តានុពលទាក់ទាញប្រភេទទេសចរណ៍សុខភាព ជាលក្ខណៈសម្រាកលម្ហែកម្សាន្ត ស្ប៉ាសុខភាព ឬការរៀបចំមណ្ឌលទេសចរណ៍សម្រាប់ភ្ញៀវវ័យចំណាស់ស្នាក់នៅរយៈពេលមធ្យម និងវែង ដោយភ្ជាប់ជាមួយប្រព័ន្ធថែរក្សាសុខភាព និងប្រភេទទេសចរណ៍ "ផ្ទះទី២"។ ទីផ្សារបែបនេះកំពុងមាននិន្នាការកើនឡើងនៅអាស៊ី ដោយសារកត្តាអាកាសធាតុ និងលក្ខណៈធម្មជាតិ ផ្សេងទៀតល្អប្រសើរ សន្តិសុខ សុវត្ថិភាពល្អ និងការចំណាយមានកម្រិតសមរម្យ។

ទោះបីបច្ចុប្បន្ន ចំនួនទេសចរអន្តរជាតិទៅកាន់តំបន់ឆ្នេរ មានប្រមាណជា១០% នៃភ្ញៀវសរុបមកកម្ពុជាក៏ដោយ ក៏ប៉ុន្តែនិន្នាការទេសចរណ៍ បានបង្ហាញការស្ទុះឡើងឆាប់រហ័សស្របតាមការរីកចម្រើននៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ។ តាមពិតទៅនៅក្នុងពិភពលោក តម្រូវការអេកូទេសចរណ៍មានសមាមាត្រប្រហាក់ប្រហែលនឹងតម្រូវការផ្នែកទេសចរណ៍វប្បធម៌ ពិសេសក្នុងសភាពការណ៍បច្ចុប្បន្នដែលមានចរន្តទប់ទល់ការកើនកំដៅជាសកល។ ចំពោះកម្ពុជា និន្នាការនេះនឹងមើលឃើញកាន់តែច្បាស់នៅពេលខាងមុខ។ តំបន់ឆ្នេរទទួលតម្រូវការទេសចរណ៍ក្នុងស្រុកច្រើនជាងភ្ញៀវអន្តរជាតិដោយហេតុថាតម្រូវការសម្រាកលម្ហែកម្សាន្តនៃភ្ញៀវក្នុងស្រុកច្រើនពិសេសពេលបុណ្យឬថ្ងៃឈប់សម្រាក ហើយការផ្សព្វផ្សាយនិងការតភ្ជាប់ជាលក្ខណៈអន្តរជាតិ នៅមានកម្រិតនៅឡើយសម្រាប់ភ្ញៀវបរទេស។ ថ្ងៃអនាគត និន្នាការនេះ នឹងប្រែប្រួលនៅពេលដែលព្រលានយន្តហោះខេត្តព្រះសីហនុ ខេត្តកោះកុង និងរមណីយដ្ឋាន ភ្នំបូកគោ បើកដំណើរការពេញលេញហើយឆ្នេរសមុទ្រកម្ពុជាដែលជាសមាជិក ក្លឹបឆ្នេរដ៏ស្អាតបំផុត ក្នុងពិភពលោកត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ។

យ៉ាងណាក៏ដោយតំបន់ឆ្នេររបស់កម្ពុជា ត្រូវអភិវឌ្ឍដោយប្រុងប្រយ័ត្ន ត្រូវមានផែនការច្បាស់លាស់ និងយន្តការអនុវត្តត្រឹមត្រូវ ជៀសវាងការប៉ះពាល់អវិជ្ជមាននានាកើតឡើងដូចប្រទេសមួយចំនួនដែលបាននិងកំពុងជួបប្រទះ។ សន្តិសុខ សុវត្ថិភាព និងផាសុខភាពត្រូវពង្រឹងនិងលើកកម្ពស់ ជាប្រចាំដើម្បីធ្វើឱ្យតំបន់ឆ្នេរក្លាយជាប៉ូលទេសចរណ៍លំដាប់អន្តរជាតិ ហើយសក្តិសមជាសមាជិកនៃក្លឹបឆ្នេរស្អាតបំផុតក្នុងលោក និងជាតារាកំពុងរះនាទិសនិរតីពិតប្រាកដ។




(រូបថតៈ ខេត្តព្រះសីហនុ កំពត កែប និងកោះកុង)

## ឃ. ភូមិភាគឦសាន

ភូមិភាគឦសានភ្ជាប់គ្នាដោយខេត្ត៤គឺ ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី។ តំបន់នេះមានសក្តានុពលទាក់ទាញផ្នែកអេកូទេសចរណ៍ ដោយផ្អែកលើមូលដ្ឋាន "សម្បត្តិវប្បធម៌ និងធនធានធម្មជាតិ" ពិសេសវប្បធម៌ ប្រពៃណីរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច និងភាពទោល នៃសត្វផ្សោតមេគង្គដ៏កម្រមានក្នុងលោក។ ក្រៅពីនេះភូមិភាគឦសានជាតំបន់សម្បូរជីវៈចម្រុះ តំបន់ការពារឧទ្យាន

ជាតិ ដូចជាឧទ្យានជាតិវីរជ័យ តំបន់រ៉ាមសារទេសភាព និងអាកាសធាតុល្អពិសេសនៅខេត្តមណ្ឌលគិរី និងភាពសម្បូរបែបនៃសត្វព្រៃ ដែលជាប្រភពទាក់ទាញទេសចរណ៍យ៉ាងសំខាន់ ដូចដែលបាននិងកំពុងអភិវឌ្ឍនៅទ្វីបអាហ្វ្រិក។ ឦសានត្រូវបានលើកកម្ពស់តាមរយៈនៃការអភិវឌ្ឍទេសចរណ៍ក្រោមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បី "កំណើនប្រសិទ្ធភាពការងារនិងសមធម៌" ពិសេសការផ្តោះទៅកាន់ទេសចរណ៍សហគមន៍ (ដើម្បីគោលដៅនៃការជួយប្រជាជនសហគមន៍ផង និងការថែរក្សា ការពារសម្បត្តិវប្បធម៌និងធនធានធម្មជាតិផង)។

រាជរដ្ឋាភិបាលយល់ច្បាស់ណាស់អំពីសារៈសំខាន់នៃទេសចរណ៍សហគមន៍ ដើម្បីការកាត់បន្ថយភាពក្រីក្រដោយមកដល់ពេលនេះឦសានមានសហគមន៍ទេសចរណ៍គំរូចំនួន៦ត្រូវបានបង្កើតនិងដំណើរការដែលគ្រប់គ្រងដោយសហគមន៍ផ្ទាល់ និងដោយមានការជួយជ្រោមជ្រែងពីក្រសួងទេសចរណ៍។ ក្រៅពីនេះនៅមានសហគមន៍ជាច្រើន ជាលក្ខណៈសហគមន៍ព្រៃឈើ សហគមន៍នេសាទ ក៏បាននិងកំពុងបញ្ចូលសកម្មភាពទេសចរណ៍ដើម្បីចំណូលបន្ថែម។ ការអនុវត្តប្រកបដោយជោគជ័យក្នុងសហគមន៍ទេសចរណ៍ទាំងអស់នេះ បានប្រែក្លាយភូមិភាគឦសានពីតំបន់ឆ្ងាយដាច់ស្រយាលទៅជាតំបន់មានការអភិវឌ្ឍ និងប្រែក្លាយធនធាននៅទីនោះទៅជាផលិតផលទេសចរណ៍។ ប្រជាជនសហគមន៍ដែលមានទម្លាប់កាប់ព្រៃ ឬបាញ់សត្វ បានប្រែក្លាយទៅជាមគ្គុទ្ទេសក៍ទេសចរណ៍ ឬជាអ្នកឧទ្ទេសនាំភ្ញៀវទស្សនាព្រៃ ឬសត្វជំនួសវិញហើយទទួលផលច្រើនជាងទម្លាប់ចាស់។ ករណីនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីនិន្នាការផែនការយកទេសចរណ៍ជាឧបករណ៍ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញលើកទឹកចិត្តការចូលរួមរបស់ប្រជាជនក្នុងការថែរក្សាការពារធនធានធម្មជាតិ។

ឦសានជាប៉ូលអាទិភាពនៃការអភិវឌ្ឍទេសចរណ៍សហគមន៍ដោយបានផ្តល់មេរៀនល្អៗជាច្រើនដល់តំបន់ផ្សេងៗទូទាំងប្រទេស។ ជាងនេះទៀត ឦសានស្ថិតក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ"ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ វៀតណាម"ដែលជាតំបន់អាទិភាពមួយក្នុងគម្រោងអភិវឌ្ឍរបស់រដ្ឋាភិបាលនៃប្រទេសទាំងបី។ តំបន់នេះត្រូវបានលើកទឹកចិត្តជំរុញការទស្សនារបស់ប្រជាជនទៅវិញទៅមកដោយសម្រាលយ៉ាងច្រើនដូចជាការអនុញ្ញាតឱ្យប្រើប្រាស់ត្រឹមបណ្ណព្រំដែនក្នុងការឆ្លងកាត់និងទស្សនាក្នុងតំបន់។ ក្រៅពីនេះ គម្រោងវិនិយោគសាធារណៈជាច្រើនរួមមាន គម្រោងហេដ្ឋារចនាសម្ព័ន្ធត្រូវបានដាក់ចេញនិងអនុវត្តក្នុងតំបន់ត្រីកោណនេះដែលរុញឱ្យឦសានកម្ពុជាកាន់តែត្រូវបានអភិវឌ្ឍ។ ថ្វីបើចំនួនភ្ញៀវទៅទស្សនាឦសាននៅមានកម្រិតតែអត្រាកំណើនខ្ពស់រហូតដល់ប្រមាណជាង៣០%ក្នុងឆ្នាំ២០១១។ តម្រូវការក្នុងស្រុកកើនឡើងខ្លាំង ពិសេសក្រោយការស្ថាបនាផ្លូវជាតិលេខ៧ និងផ្លូវទៅកាន់ខេត្តមណ្ឌលគិរី ស្ពានឆ្លងទន្លេសេកុង (ខេត្តស្ទឹងត្រែង) ផ្លូវតភ្ជាប់ស្ទឹងត្រែង រតនគិរី និង មណ្ឌលគិរី។ កំណើននេះពេលខ្លះបង្កការលំបាក និងចោទជាបញ្ហាស្តីពីការខ្វះសេវាកម្មស្នាក់នៅក្នុងខេត្ត ភូមិភាគឦសាន។

កត្តាអាទិភាពនៃការអភិវឌ្ឍផលិតផលទេសចរណ៍នៅភូមិភាគនេះ គឺការបន្តសកម្មឡើងនៃទេសចរណ៍សហគមន៍អេកូទេសចរណ៍ ការរីករាយកម្សាន្តប្រកបដោយការទទួលខុសត្រូវជាមួយធម្មជាតិ និងការប្រើប្រាស់ប្រកបដោយមនសិការនូវសម្បត្តិវប្បធម៌និងធនធានធម្មជាតិដើម្បីការអភិវឌ្ឍទេសចរណ៍។ ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចតភ្ជាប់គោលដៅទាក់ទាញទេសចរណ៍ត្រូវបន្តពង្រឹងនិងពង្រីកដើម្បីតភ្ជាប់ទីជនបទទាំងនេះឱ្យទៅជាគោលដៅទេសចរណ៍។ សម្បទាទេសចរណ៍នានា ក្នុងនោះសេវាកម្មស្នាក់នៅដូចជាសណ្ឋាគារផ្ទះសំណាក់ ផ្ទះស្នាក់របស់ប្រជាជនត្រូវរៀបចំ និងបង្កលក្ខណៈ ជូនប្រជាជនពិសេសអ្នករស់នៅក្នុងស្រុកដែលទទួលផលពីការរីកចម្រើននេះ។ ការវិនិយោគទ្រង់ទ្រាយធំ ត្រូវស្វាគមន៍ ប៉ុន្តែបើកម្រិតវិនិយោគមធ្យមឬតូចគួរត្រូវបានពិចារណាលទុកជូនប្រជាជនសហគមន៍ មូលដ្ឋានគ្រប់គ្រង និងប្រតិបត្តិវិញ។

ភូមិភាគឦសានមានប្រព័ន្ធផ្លូវតភ្ជាប់ល្អប្រសើរ ក្នុងនោះផ្លូវលេខ៧ លេខ៨ និងលេខ៧៦ និងមានតម្រូវការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធបន្ថែមដើម្បីឱ្យតំបន់នេះមានសមត្ថភាពពេញលេញក្នុងការទាក់ទាញទេសចរទាំងជាតិនិងអន្តរជាតិ ពិសេសការប្រែក្លាយជាប៉ូល(មេដែកថ្មីមួយទៀត) មិនគ្រាន់តែកម្ពុជាប៉ុណ្ណោះទេគឺតំបន់ត្រីកោណទាំងមូល។ ព្រលានយន្តហោះខ្នាតអន្តរជាតិកម្រិតមធ្យមមួយចាំបាច់ត្រូវស្ថាបនាឡើងនៅភូមិភាគឦសាន ពិសេសក្នុងខេត្តរតនគិរីដើម្បីបម្រើទាំងការដឹកជញ្ជូនទេសចរនិងទាំងការដឹកទំនិញកសិកម្ម និងផលិតផលរ៉ែ។ ព្រលានយន្តហោះនេះនឹងដើរតួនាទីជាស្នូលនៃតំបន់ត្រីកោណ ព្រោះថាខេត្តតំបន់នោះជាច្រើនទាំងកម្ពុជា ឡាវ និងវៀតណាម ពុំទាន់មានព្រលានយន្តហោះជាលក្ខណៈអន្តរជាតិនៅឡើយ។

វាលយន្តហោះ(លក្ខណៈក្នុងស្រុក) គួរត្រូវពិចារណាសិក្សាក្នុងការស្តារឡើងវិញនៅលើទីតាំងដែលមានស្រាប់ឬទីតាំងថ្មីនៅខេត្តក្រចេះ ខេត្តស្ទឹងត្រែងឬខេត្តមណ្ឌលគិរី ក្នុងនោះខេត្តក្រចេះ មានអាទិភាពជាងដោយសារភាពទាក់ទាញនៃសត្វផ្សោត និងការឃ្លាតឆ្ងាយពីខេត្តរតនគិរីធៀបនឹងខេត្តពីរទៀត។ វាលយន្តហោះនេះនឹងប្រើជាលក្ខណៈក្នុងស្រុកតភ្ជាប់ជាមួយរាជធានីភ្នំពេញខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តបាត់ដំបង ឬវាលយន្តហោះខេត្តព្រះវិហារក្នុងថ្ងៃអនាគត។



(រូបថតៈ ភូមិភាគឦសាន ខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគីរី រតនគីរី)

### ខ. តំបន់ជុំវិញបឹងទន្លេសាប

បឹងទន្លេសាបមិនគ្រាន់តែជាជម្រកត្រីដ៏សម្បូរបែបប៉ុណ្ណោះទេ តែថែមទាំងជាតំបន់ដែលផ្តល់នូវផលិតផលទេសចរណ៍ច្រើនយ៉ាងទាំង"វប្បធម៌និងធម្មជាតិ" ពិសេសការតភ្ជាប់ជាមួយតំបន់ទេសចរណ៍អង្គរ និងភាពសម្បូរនៃជីវៈចម្រុះនៅក្នុងជីវមណ្ឌលនៃបឹងទន្លេសាប។ ទេសចរណ៍ និង ជីវៈចម្រុះផ្សារភ្ជាប់គ្នា និងគាំទ្រគ្នាទៅវិញទៅមក មានន័យថាការអភិវឌ្ឍទេសចរណ៍ គឺរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹង ការស្រឡាញ់និងការការពារថែរក្សជីវៈចម្រុះ និងប្រភពធនធានធម្មជាតិ និងវប្បធម៌។

តំបន់បឹងទន្លេសាបភ្ជាប់ដោយខេត្តនៅជុំវិញដែលមានសក្តានុពលទេសចរណ៍។ ក្រៅពីតំបន់អង្គរដ៏ល្បីល្បាញ តំបន់នេះ គឺជាតំបន់អេកូទេសចរណ៍ដ៏ធំបំផុត និងជាតំបន់ដែលមានលទ្ធភាពក្នុងការអភិវឌ្ឍយ៉ាងឆាប់រហ័សឱ្យទៅជាគោលដៅទេសចរណ៍លំដាប់អន្តរជាតិ។ លទ្ធភាពចម្បង៥ ដែលតំបន់នេះមាននោះគឺ (១)ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ល្អប្រសើរទាំងផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស ពិសេសផ្លូវជាតិលេខ៥ និងលេខ៦ ភ្ជាប់រាជធានីភ្នំពេញទៅព្រំដែនប្រទេសថៃ។ (២)ការធ្វើនាវាចរណ៍និងការទស្សនាកម្សាន្តតាមផ្លូវទឹក ទស្សនាតាមភូមិអ្នកនេសាទ ភូមិបណ្តែតទឹក ព្រៃលិចទឹក តំបន់ជម្រកសត្វ តំបន់នេសាទ។ល។ ការអភិវឌ្ឍជាប្រភេទនាវាទេសចរណ៍កម្រិតអន្តរជាតិសម្រាប់ការលំហែកម្សាន្តនៅលើផ្ទៃបឹងទន្លេសាប

ដែលមានទេសភាពដ៏ស្រស់ស្អាតនឹងផ្តល់ជម្រើសថ្មីដល់ទេសចរ បន្ថែមទៀត។ (៣)ការរៀបចំសហគមន៍ទេសចរណ៍ថ្មី ឬបញ្ចូលសកម្មភាពទេសចរណ៍ទៅក្នុង សហគមន៍នានាដែលមានស្រាប់ដើម្បីបង្កើតផលិតផលផង និងជួយផ្តល់ប្រយោជន៍ជូនប្រជាជន សហគមន៍ផង ដែលផលទេសចរណ៍នេះនឹងជួយបន្ថែមលើចំណូលដែលប្រជាជនធ្លាប់មាន។ (៤)ក្រៅពីខេត្តសៀមរាបដែលបាននិងកំពុងអភិវឌ្ឍទេសចរណ៍យ៉ាងសកម្ម ខេត្តផ្សេងៗទៀតមានសក្តានុពលច្រើនតែការអភិវឌ្ឍនៅមានកម្រិតនៅឡើយដែលទាមទារការជំរុញអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ឬមេដែកធក់"រណប"របស់តំបន់អង្គរ ក្នុងនោះរួមមានខេត្តទាំងឡាយនៅតាមដងផ្លូវជាតិលេខ៥ដែលជាផ្នែកដ៏សំខាន់មួយនៃផ្លូវ"អាស៊ាន"តភ្ជាប់រាជធានីភ្នំពេញ បាងកក និងក្រុងហូជីមិញ។ ខេត្តបាត់ដំបងជាមេដែកមួយនៃតំបន់នេះដែលមានសក្តានុពលទាក់ទាញទេសចរណ៍ខ្លាំងណាស់ដូចជាប្រាង្គប្រាសាទបុរាណនៅឯកភ្នំ ស្រុកបាណន ផ្ទះខ្មែរបុរាណ អគារស្ថាបត្យកម្ម ប្រវត្តិសាស្ត្រ តំបន់ទេសភាពធម្មជាតិ និងការរៀបចំដូចជានៅបឹងកំពីងពួយ រមណីយដ្ឋានជ្រលងបព្វតា ព្រៃកទ័ល។ល។ ខេត្តបាត់ដំបង គឺជាស្នូលនៃតំបន់ក្នុងការ តភ្ជាប់ទៅខេត្តផ្សេងៗ ក្នុងនោះមានខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ ដែលជាខេត្តជាប់ព្រំដែនដ៏សំខាន់។ ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង បច្ចុប្បន្នគ្រាន់តែជាខេត្តឆ្លងកាត់របស់ទេសចរវាងរាជធានីភ្នំពេញ និងខេត្តបាត់ដំបងប៉ុណ្ណោះមិនទាន់ មានការអភិវឌ្ឍពេញលេញនៅឡើយ។ ការពិតខេត្តទាំងនេះមានធនធានច្រើនដែលមិនទាន់កែច្នៃឱ្យ ទៅជាផលិតផលទេសចរណ៍ ក្នុងនោះរួមមានតំបន់កេរដំណែលប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណីរបស់ប្រជាជន ដូចជាការផលិតក្អមឆ្នាំងសិប្បកម្មកែច្នៃ វត្ថុអនុស្សាវរីយ៍ធ្វើអំពីថ្ម ឬវត្ថុជាតុផ្សេងៗ ព្រៃលិចទឹក តំបន់នេសាទ និងសហគមន៍ ប្រជាជននៅតាមដងទន្លេ និងបឹងទន្លេសាប និងតំបន់ទេសភាព ធម្មជាតិជាច្រើនទៀត ពិសេសតំបន់ភ្នំក្រវាញក្នុងនោះវារីអគ្គិសនីអាតៃនៅខេត្តពោធិ៍សាត់ នឹងក្លាយជា តំបន់អេកូទេសចរណ៍ដ៏មានភាពទាក់ទាញ។ តំបន់ជុំវិញបឹងទន្លេសាប គឺជាជង្រុកនៃផលិតផលក្នុងស្រុក ដូចជា អង្ករ បន្លែ ត្រី សាច់ផ្លែឈើ។ល។ ដើម្បីផ្គត់ផ្គង់ ទេសចរណ៍ជំនួសការនាំចូលពីបរទេស។ ភាពល្បី និងពេញនិយមនៃអង្ករធ្ងាញ់(មិនប្រើជីគីមី) នៃខេត្តបាត់ដំបង ក្រូចពោធិ៍សាត់ និងត្រីស្រស់ៗមកពីបឹងទន្លេសាប និងផលិតផលផ្សេងៗជាច្រើនទៀតបាននិងកំពុងស្រូបទាញទេសចររាប់លាននាក់មកកាន់តំបន់នេះ ពិសេសទេសចរក្នុងស្រុករួមទាំងជនបរទេសបម្រើការងារនៅកម្ពុជា។

យ៉ាងណាក៏ដោយ ដើម្បីឈានទៅសម្រេចចក្ខុវិស័យឆ្នាំ២០២០និងទៅមុខទៀត តំបន់ជុំវិញបឹងទន្លេសាប ត្រូវបានយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និង ការទទួលខុសត្រូវគ្រប់ភាគីពាក់ព័ន្ធរួមទាំងប្រជាជន។ ការអភិវឌ្ឍត្រូវមានផែនការច្បាស់លាស់ និង អនុវត្តត្រឹមត្រូវជៀសវាងបច្ច័យអវិជ្ជមាននាថ្ងៃអនាគត។ ក្រសួងទេសចរណ៍សហការជាមួយស្ថាប័នពាក់ព័ន្ធអង្គការជាតិ និងអន្តរជាតិ ពិសេស UNESCO និងដោយមានការគាំទ្រពីប្រទេសអូស្ត្រាលី បាននិងកំពុងរៀបចំសិក្សាដើម្បីឈានទៅកសាងផែនការមេផែនការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពជុំវិញបឹងទន្លេសាប។

ជាយុទ្ធសាស្ត្រតំបន់នេះ ត្រូវបន្ថែមហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួនទៀតដើម្បីត្រៀមលក្ខណៈស្របយកនិងទទួលតម្រូវការទេសចរណ៍ដ៏ខ្លាំងនាពេលដ៏ខ្លីខាងមុខ។ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ រួមមាន (១)កំពង់ផែទេសចរណ៍នៅខេត្តបាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំង (២)ស្ថានីយចំណតទេសចរណ៍តាមដងផ្លូវជាតិលេខ៥និងលេខ៦ បន្ថែមលើគម្រោងដែលកំពុងសាងសង់នៅខេត្តពោធិ៍សាត់។ ជំហានដំបូងមានការអភិវឌ្ឍស្ថានីយចំណតតាមដងផ្លូវដែលមានស្រាប់របស់ប្រជាជនឱ្យ បានប្រសើរឡើងទាំងសោភ័ណភាព គុណភាពនិងអនាម័យដើម្បីទទួលទេសចរ។ (៣)ស្តារព្រលាន យន្តហោះខេត្តបាត់ដំបងឡើងវិញ និងឈានទៅដំណើរការជាលក្ខណៈក្នុងស្រុក ដោយភ្ជាប់ការហោះហើរ ជាមួយរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តព្រះវិហារ និងភូមិភាគឦសាន។ (៤)ការរៀបចំធ្វើឱ្យប្រសើរឡើងផ្នែកបរិស្ថានទេសចរណ៍នៅតាមទីក្រុង និងទីប្រជុំជនក្នុងតំបន់ពិសេស ការរៀបចំប្រព័ន្ធសម្អាតកាកសំណល់រឹងនិងរាវក្នុងនោះប្រព័ន្ធសម្អាតទឹកប្រើប្រាស់រួច ទីក្រុងបាត់ដំបងគួរត្រូវផ្តល់អាទិភាព។



(រូបថតៈ តំបន់ជុំវិញបឹងទន្លេសាប)

## ច. តំបន់តាមដងទន្លេមេគង្គ និងទន្លេបាសាក់

តំបន់នេះភ្ជាប់ភូមិភាគឦសាន ត្រង់ខេត្តក្រចេះ មកដល់ព្រំដែនជាមួយប្រទេសវៀតណាមនៃទឹកដីខេត្តស្វាយរៀង និងខេត្តតាកែវ។ តំបន់នេះមានកម្រិតដង់ស៊ីតេប្រជាជនខ្ពស់ជីវភាពរស់នៅល្អប្រសើរ និងមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរីកចម្រើន។ ការអភិវឌ្ឍទេសចរណ៍ក៏បាននិងកំពុងបោះជំហានទៅមុខយ៉ាងសកម្ម ដោយសារតំបន់នេះនៅជាប់ជាមួយរាជធានីភ្នំពេញដែលជាប៉ូលដ៏សំខាន់ ដូចតំបន់ឯទៀតដែរ តំបន់មេគង្គនេះមានសក្តានុពលទេសចរណ៍ "វប្បធម៌និងធម្មជាតិ" ជាច្រើនដែលមិនទាន់ត្រូវបានអភិវឌ្ឍដើម្បីស្រូបយកផលពីទេសចរណ៍ឱ្យបានពេញលេញនៅឡើយ ដូចជាប្រាសាទបុរាណ និងតំបន់ប្រវត្តិសាស្ត្រនៅខេត្តកំពង់ចាមរួមមាន ប្រាសាទវត្តនគរ ភ្នំហាន់ជ័យ ភ្នំប្រុសភ្នំស្រី តំបន់ ហ្លួងព្រះស្ដេចកន ។ល។ ខេត្តតាកែវនៅអង្គរបុរី អតីតរាជធានីទី១នៃអាណាចក្រខ្មែរ ភ្នំជីសូរ ទន្លេបាទី ភ្នំបាយ៉ង់កោនៅស្រុកគីរីវង្សដែលមានប្រវត្តិដ៏យូរលង់ និងភាពទាក់ទាញផ្នែកអេកូទេសចរណ៍ផងដែរ។

ក្រៅពីនេះ តំបន់នេះនៅមានភាពទាក់ទាញពីវប្បធម៌ប្រពៃណី ប្រវត្តិសាស្ត្រនៃប្រជាជនដែលភាគច្រើនជា កសិករ និងសហគមន៍ប្រជាជនរស់នៅតាមដងទន្លេ ខេត្តកំពង់ចាម ខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តតាកែវ ដែលតំបន់នេះអាចផ្ដល់ជូនទេសចរនូវផលិតផលកសិទេសចរណ៍ និងវប្បធម៌នៃការរស់នៅរបស់ប្រជាជន និងតំបន់ប្រវត្តិសាស្ត្រជាច្រើន។



(រូបភាព: តាមដងទន្លេមេគង្គ និងទន្លេសាប)

## III. **សន្និដ្ឋាន**

ជារួមតំបន់អទិភាពទាំង៦នេះត្រូវបានរៀបចំឡើងដោយ ក្រសួងទេសចរណ៍ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ឆ្នាំ២០១២-២០២០ ដែលបានទទួលឯកភាពពីគណរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២។ រយៈពេល៦ឆ្នាំកន្លងមកនេះ តំបន់អទិភាពមួយចំនួនមានការប្រែប្រួលតិចតួច និងតំបន់អទិភាពមួយចំនួនមានការប្រែប្រួលខ្លាំងដែលទាមទារនូវការសិក្សាស្រាវជ្រាវមួយ ដ៏ច្បាស់លាស់ដើម្បីស្វែងរកជាតុចូលដាក់ជូនរាជរដ្ឋាភិបាល សំរាប់ចូលរួមក្នុងការចងក្រងនូវផែនការយុទ្ធសាស្ត្រថ្មីមួយ ដែលសមស្របទៅតាមលក្ខខណ្ឌសង្គមបច្ចុប្បន្ន។ តំបន់សៀមរាបអង្គរនិងតំបន់ជុំវិញភាពកកកុញនៃកំណើនភ្ញៀវទេសចរទៅទស្សនាតំបន់អង្គរនៅបន្តកើនឡើងជាលំដាប់ ដែលជាកង្វល់មួយនៃភាពវិចវិលតំបន់បេតិកភណ្ឌពិភពលោកមួយនេះ។ ការបង្កើតផលិតផលថ្មីៗនៃតំបន់ជុំវិញ អង្គរបន្តអនុ

វត្ថុយ៉ាងសកម្មដូចជា ការបង្កើតសហគមន៍ទេសចរណ៍កំពង់ភ្លុក កំពង់ឃ្លាំង ព្រែកទ័ល មេជ្រៃ និងសហគមន៍ទេសចរណ៍បន្ទាយស្រីជាដើម ដែលបានជួយសម្រួលនិងពន្យាពេលនៃការស្នាក់នៅរបស់ ទេសចរបានមួយកម្រិតបន្ថែមទៀត។ រាជធានីភ្នំពេញនៅតែជាកង្វល់សម្រាប់ប្រជាពលរដ្ឋ និងទេសចរ អន្តរជាតិទាក់ទងនឹងបញ្ហាចរាចរណ៍ និងសម្រាម។ តំបន់ឆ្នេរ ជាពិសេសខេត្តព្រះសីហនុ ទោះបីជាសន្ទុះនៃការអភិវឌ្ឍយ៉ាងខ្លាំងក្លា នៃហេដ្ឋារចនាសម្ពន្ធ័ទេសចរណ៍ដ៏សម្បូរបែប ប៉ុន្តែបញ្ហាប្រឈមចំពោះ មុខជាច្រើនទាក់ទងនឹងបញ្ហាសេវាស្នាក់នៅ បរិស្ថាន ស្ថាបត្យកម្ម និងកំណើននៃទេសចរជនជាតិចិន គឺជាបញ្ហាដែលត្រូវដោះស្រាយចំពោះមុខ។ ភូមិភាគឦសានគឺជាតំបន់ដែលសម្បូរទៅដោយសម្បត្តិ ធនធានដ៏សម្បូរបែបលើវិស័យអេកូទេសចរណ៍ ផលិតផលទេសចរណ៍ថ្មីៗជាច្រើនត្រូវបានបង្កើតឡើង។ ដើម្បីគាំទ្រលើវិស័យអេកូទេសចរណ៍នេះរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិ អេកូ ទេសចរណ៍២០១៩-២០៣០ អនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

ទោះបីជាក្រសួងទេសចរណ៍បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ និងវិធានផ្សេងៗទាក់ទងនឹងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបភាពប្រកួតប្រជែង និងបរិយាប័ន្នយ៉ាងណាក្តី ក៏របាយការណ៍ដែលចេញដោយធនាគារពិភពលោកកាលពីឆ្នាំ២០១៧ បានអោយដឹងថាការប្រកួតប្រជែង ផ្នែកការធ្វើដំណើរ និងទេសចរណ៍របស់ប្រទេសកម្ពុជានៅមានកម្រិតទាបនៅឡើយ។ ថ្វីបើប្រទេសកម្ពុជាបានឈានឡើង ៤ លេខក្នុងឆ្នាំ២០១៧ក្តី ប៉ុន្តែកម្ពុជានៅតែជាប់ចំណាត់ថ្នាក់ទី១០១ក្នុងចំណោមប្រទេស១៣៦ នៅទូទាំងសាកលលោក។ កត្តាជម្រុញចម្បង ដែលជាមូលដ្ឋាននៃភាពប្រកួតប្រជែងវិស័យការធ្វើដំណើរ និងទេសចរណ៍របស់កម្ពុជាគឺគោលនយោបាយ និងយុទ្ធសាស្ត្រជាទូទៅរបស់អាជ្ញាធរ។ គោលនយោបាយនិងយុទ្ធសាស្ត្រទាំងអស់នោះរួមមានដូចជា ចាត់អទិភាពវិស័យទេសចរណ៍និងធ្វើដំណើរ(ចំណាត់ថ្នាក់ ទី២៩) តម្លៃមានលក្ខណៈប្រកួតប្រជែង(ទី៥១) ភាពបើកចំហជាអន្តរជាតិ (ទី៥៨) ធនធានធម្មជាតិ (ទី៦២) និងធនធានវប្បធម៌(ទី៧៦)។ ទោះបីយ៉ាងណាក្តី លទ្ធផលរបស់កម្ពុជានៅមានភាពយឺតយ៉ាវ ផ្នែកនិរន្តភាពបរិស្ថាន (ទី១៣០) បរិស្ថានអជីវកម្ម(ទី១២៥) ធនធានមនុស្សនិងទីផ្សារការងារ (ទី១១០) សុខភាពនិងអនាម័យ(ទី១០៩) ហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក(ទី១០៨) និងហេដ្ឋារចនាសម្ព័ន្ធ ទេសចរណ៍ (ទី១០២)។ ការប្រៀបធៀបភាពប្រកួតប្រជែងការធ្វើដំណើរ និងទេសចរណ៍នៅតាមបណ្តា ប្រទេសជាច្រើនក្នុងតំបន់ចង្អុលបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាដើរក្រោយប្រទេសជាមិត្តរបស់ខ្លួន ថ្វីបើកម្ពុជាមានធនធានធម្មជាតិ និងវប្បធម៌ទុនក្តី។ ថ្វីបើទាក់ទងជាមួយធនធានធម្មជាតិ និងវប្បធម៌ ប្រទេសកម្ពុជាគឺជាប្រទេសទីពីរប៉ុណ្ណោះបន្ទាប់ពីប្រទេសវៀតណាមក្តី ប៉ុន្តែភាពប្រកួតប្រជែងផ្នែក ទេសចរណ៍ជាទូទៅរបស់ប្រទេសកម្ពុជា ជាប់លំដាប់លេខ១០១ នៅពីក្រោយសាធារណរដ្ឋប្រជាធិបតេយ្យ ឡាវដែលជាប់ចំណាត់ថ្នាក់លេខ ៩៤ ប្រទេសវៀតណាមជាប់ចំណាត់ថ្នាក់លេខ៦៧ និងប្រទេសថៃជាប់ ចំណាត់ថ្នាក់លេខ៣៤។

**ឯកសារយោង៖**

- រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០
- រាជរដ្ឋាភិបាល គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០
- ធនាគារពិភពលោក បច្ចុប្បន្នសេដ្ឋកិច្ចកម្ពុជា "កម្ពុជាបោះជំហានឈានឡើងតាមសង្វាក់តម្លៃនៃកម្មន្តសាល" (ខែតុលា ឆ្នាំ២០១៧)